54

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តក្រចេះ**

សំណុំរឿងរដ្ឋប្បវេណីលេខ០៤៧
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩
សាលក្រមលេខៈ ៣៣ (ក)
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តក្រចេះ

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់
នាថ្ងៃទីម្ភៃប្រាំ ខែមិនា ឆ្នាំពីរពាន់ម្ភៃ លើសំណុំរឿងរដ្ឋប្បវេណីលេខ ០៤៧
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដែលមានសមាសភាពចុះឈ្មោះដូចតទៅ

**ចៅក្រមជំនុំជម្រះ**

**លោកស្រី [redacted] ប្រធានសាលាដំបូងខេត្តក្រចេះ**

**ក្រឡាបញ្ជីសវនាការ**

**លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តក្រចេះ**

**-ដើមចោទ:** ក្រុមហ៊ុន [redacted] តំណាងដោយឈ្មោះ [redacted] ប៊ុនណាត ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិ[redacted]។

**-ចុងចម្លើយ:** ឈ្មោះ [redacted] សេងថៃ និងប្រពន្ធឈ្មោះ [redacted] ចំណោះ មានទីលំនៅ[redacted]ៈ។

-មេធាវីតំណាងរាជរដ្ឋាភិបាលលោក[redacted]។

**១/អំពីអង្គហេតុ**

១.១.ខ្លឹមសារនៃការទាមទាររបស់ដើមចោទ

-សុំបដិសេធលិខិតបញ្ជាក់របស់លោកមេភូមិអូរគ្រៀងចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥។

-សុំបដិសេធលិខិតបញ្ជាក់លោកមេឃុំអូរគ្រៀងលេខៈ ១០៩៦ /ឃ រ ត.. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥។

-សុំបដិសេធលិខិតផ្ទេរសិទ្ធកាន់កាប់បន្តលេខៈ១០៦/២០១០ ឃអរគ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១។

-សុំបដិសេធលិខិតផ្ទេរសិទ្ធកាន់កាប់បន្តលេខៈ ១០៧/២០១០ ឃអរគ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១។

១.២.អង្គហេតុនៃរឿងក្តី

កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រុមហ៊ុន[redacted] បានស្នើសុំចុះបញ្ជីដីទំហំ៦៤៤,៤២ហិកតា និងសុំសាងសង់រោងចក្រកែច្នៃដំឡូងមី ដែលមានទីតាំងស្ថិតនៅភូមិអូរគ្រៀង ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ទៅលោកអភិបាលខេត្តក្រចេះរួចហើយ។ លុះដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ក្រុមហ៊ុនបានទិញដីពីឈ្មោះ [redacted] វណ្ណៈ ដើម្បីឲ្យគ្រប់ទិន្នន័យតាមពាក្យស្នើសុំចុះបញ្ជីដីរបស់ក្រុមហ៊ុន។

បកដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ បានកំណត់ហេតុស្តីពីការប្រជុំពិនិត្យ និងពិភាក្សាលើសំណើសុំចុះបញ្ជីដីរបស់ក្រុមហ៊ុន[redacted] ទីតាំងស្ថិតនៅភូមិ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្ត

ក្រចេះ លទ្ធផលនៃការប្រជុំមានឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត បានឯកភាពតាមយោបល់របស់អង្គប្រជុំ និងបានស្នើសុំឲ្យលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរៀបចំឯកសារតាមនីតិវិធី សុំទៅថ្នាក់ជាតិដើម្បីចុះបញ្ជីជូនក្រុមហ៊ុនឲ្យបានឆាប់។

-នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ មានចំណារបានឃើញ និងឯកភាពលើផែនទីបង្ហាញទីតាំងដីស្នើសុំចុះបញ្ជីជាកម្មសិទ្ធិរបស់ក្រុមហ៊ុន [redacted] ស្ថិតនៅភូមិ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ របស់៖

-លោកមេឃុំអូរគ្រៀង

-លោកប្រធានការិយាល័យ រៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកសំបូរ

-លោកអភិបាលស្រុកសំបូរ

-លោកនាយខ័ណ្ឌរដ្ឋបាលព្រៃឈើក្រចេះ

-លោកប្រធានមន្ទីរបរិស្ថានខេត្ត

-លោកប្រធានមន្ទីរកសិកម្មខេត្ត

-លោកប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

-ចំណារ ឯកភាពរបស់ឯកឧត្តមអភិបាលខេត្ត ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ លោកអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកាត់ផ្ទៃដីទំហំ ៦៤៤,៤២ ហិចតា នៅភូមិអូរគ្រៀង ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងដីមានដីកាដកហូតដើម្បីធ្វើអនុបយោគ ជាដីឯជនរបស់រដ្ឋសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនក្រុមហ៊ុន ហ្វ៊ូឡាយឈុន (ខេមបូឌា) ត្រេឌីង។

យោងលិខិតលេខៈ ៩៦២ កសក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម។

-ចំណារ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានសម្រេចយល់ព្រមកាត់ផ្ទៃដីទំហំ ៦៤៤,៤២ ហិចតា នៅភូមិអូរគ្រៀង ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងដីកាដកហូត ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្ម ជាកម្មសិទ្ធិជូនក្រុមហ៊ុន ហ្វ៊ូឡាយឈុន(ខេមបូឌា) ត្រេឌីង សម្រាប់សាងសង់រោងចក្រកែច្នៃដំឡូងមី តាមលិខិតលេខៈ ១២៩ ស.ជ.ណ.ក.ស. ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

យោងលិខិតលេខៈ១២៩ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

លិខិតលេខៈ ១៥២២ កសក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការធ្វើអនុបយោគ តាមលិខិតលេខៈ ៥៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ សម្រេចត្រូវបានចាត់បញ្ចូលជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦៤៤,៤២ ហិចតា នៅភូមិអូរគ្រៀង ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងដីមានដីកាដកហូតដូចមានផែនទី និងនិយាមការ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាខេត្តក្រចេះ សម្រាប់ប្រទានកម្ម ជាកម្មសិទ្ធិជូន[redacted] សម្រាប់សាងសង់រោងចក្រកែច្នៃដំឡូងមី។

ក្រោយពីទទួលបានអនុក្រឹត្យ ក្រុមហ៊ុនបានបំពេញតាមនីតិវិធីដើម្បីធ្វើការចុះបញ្ជីដី និងឈានទៅដល់ការបោះបង្គោលព្រំ កាយព្រំក្បាលដី។

មកដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ស្រាប់តែមានឈ្មោះ [redacted] ចំណាន ភេទស្រី និងបក្សពួកប្រុស ស្រី ០៥នាក់ (ជាចុងចម្លើយ) មកភាំង និងអះអាងថា: ដីដែលក្រុមហ៊ុនទទួលបានអនុក្រឹត្យពីរាជរដ្ឋាភិបាលប្រទានកម្មជាកម្មសិទ្ធិ ជូនក្រុមហ៊ុន [redacted] សម្រាប់សាងសង់រោងចក្រកែឆ្នៃដំឡូងមី ថាដីនៅចំណុចកំពង់កាយព្រំនោះជាដីរបស់ពួកគេ។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ក្រុមហ៊ុនបានដាក់ពាក្យប្ដឹងទៅអាជ្ញាធរឃុំអូរគ្រៀង ប្ដឹងពីឈ្មោះ [redacted] ចំណាន និងបក្សពួកបានមករាំងឃាត់គ្រឿងចក្រកំពុងកាយព្រំក្បាលដីរបស់ក្រុមហ៊ុន។

ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ លោកមេឃុំអូរគ្រៀង បានកោះអញ្ជើញភាគីទាំងសងខាង មកប្រជុំដើម្បីដោះស្រាយបញ្ហាទំនាស់ដីធ្លីដូចខាងលើ ចំនួន០៣លើក តែពុំបានទទួលលទ្ធផលជាវិជ្ជមានទេ ដូចមានយោងក្នុងកំណត់ហេតុធ្វើនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ក្រុមហ៊ុនបានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារចូលមក សាលាដំបូងខេត្តក្រចេះ។

សាលាដំបូងខេត្តក្រចេះ បានចេញដីកាសម្រេចរក្សាការពារ តាមលិខិតលេខ: ១២ ព.ស /១៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តក្រចេះ។

នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ លោកអភិបាលស្រុកសំបូរ ជាប្រធានគណៈកម្មការដោះស្រាយវិវាទទំនាស់ដីធ្លីថ្នាក់ស្រុក បានកោះអញ្ជើញភាគីទាំងសងខាង មកចូលប្រជុំដោះស្រាយទំនាស់រឿងដីធ្លីដូចខាងលើ តែការប្រជុំលទ្ធផលអវិជ្ជមាន ដូចមានយោងក្នុងកំណត់ហេតុធ្វើនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ភាគីក្រុមហ៊ុនបានដាក់ពាក្យបណ្ដឹងចូលមកសាលាដំបូងខេត្តក្រចេះ ទាមទារឲ្យតុលាការបដិសេធលិខិតរួមមាន៖

-សុំបដិសេធលិខិតបញ្ជាក់លោកមេភូមិអូរគ្រៀងចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ។

-សុំបដិសេធលិខិតលេខ:១០៩៥/១៥ ឃអគ បញ្ជាក់របស់លោកមេឃុំអូរគ្រៀងចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ។

-សុំបដិសេធលិខិតលេខ:១០៩៦/១៥ ឃអគ បញ្ជាក់របស់លោកមេឃុំអូរគ្រៀងចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ។

-សុំបដិសេធលិខិតផ្ទេរសិទ្ធកាន់កាប់បន្តលេខ: ១០៦ / ២០១០ ឃអគ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១។

-សុំបដិសេធលិខិតផ្ទេរសិទ្ធកាន់កាប់បន្តលេខ: ១០៧ / ២០១០ ឃអគ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១។

១.៣.ការអះអាងរបស់គូភាគី

ក).ការអះអាងភាគីដើមចោទ

ក្រុមហ៊ុន [redacted] តំណាងដោយលោក [redacted] បានអះអាងថា ៖ ដីមានទំហំទទឹង ១០០ម x ៤០០ម ស្ថិតនៅភូមិអូរគ្រៀង ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ជាដីដែល



Scanned with CamScanner

ក្រុមហ៊ុនបានទិញពីឈ្មោះ [redacted] វណ្ណៈ មានលិខិតផ្ទេរសិទ្ធិកាន់កាប់បន្តពីឈ្មោះ [redacted] ញ៉ូន ជាម្ចាស់ដីមានការបញ្ជាក់ពីមេភូមិ និងមេឃុំអូរគ្រៀងតាមលិខិតលេខៈ ៣៨/០៣ ឃអគ្រ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៣ និងលិខិតលេខៈ ៥៨/០៣ ឃអគ្រ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៣ ប្រាកដមែន។

ខ).ការអះអាងរបស់ភាគីចុងចោទ

លោកមេធាវីតំណាងអាណត្តិរបស់ចុងចម្លើយលោក [redacted] បានអះអាងថា ៖ ស្នើសុំឲ្យតុលាការលើកចោលពាក្យបណ្ដឹងរបស់ដើមចោទ និងទទួលស្គាល់ពាក្យបណ្ដឹងតាមរយៈកូនក្តីខ្លួន។ កូនក្តីខ្លួនមានឯកសារត្រឹមត្រូវ និងមានសាក្សីច្បាស់លាស់។

១.៣.តាមការទាញហេតុផលដោយផ្ទាល់មាត់

-ចុងចម្លើយឈ្មោះ [redacted] សេងថៃ និងឈ្មោះ [redacted] ចំណាន និងលោកមេធាវី [redacted] អវត្តមានដោយសុំពន្យាពេលការទាញហេតុផលដោយផ្ទាល់មាត់។

-ដើមចោទឈ្មោះ [redacted] តំណាងអោយក្រុមហ៊ុន បានបញ្ជាក់អះអាងថា ៖ ដីដែលមានទំនាស់នេះជាដីដែលក្រុមហ៊ុនបានទិញពីឈ្មោះ [redacted] វណ្ណៈ ដែលមានម្ចាស់ដើមឈ្មោះ [redacted] ញ៉ូន ។ ខ្លួនមានសាក្សីគ្រប់គ្រាន់ និងសុំបដិសេធរាល់លិខិតទាំងអស់ ទៅតាមពាក្យបណ្ដឹងរបស់ខ្លួនដដែល។

-សាក្សីឈ្មោះ [redacted] តុន ជាមេភូមិអូរគ្រៀងបានអះអាងថា ៖ ចាប់ពីឆ្នាំ១៩៩៦មក ខ្លួនបានធ្វើជាមេភូមិរហូតដល់សព្វថ្ងៃនេះ។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៣ ខ្លួនបានចុះហត្ថលេខាលើលិខិតកាន់កាប់ដីរបស់ឈ្មោះ [redacted] ញ៉ូន ប្រាកដមែន។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៣ ឈ្មោះ [redacted] ញ៉ូន បានលក់ដីនោះឲ្យទៅឈ្មោះ [redacted] វណ្ណៈ ដោយមានភ្ជាប់លិខិតកាន់កាប់ដីលេខៈ៣៨/០៣ ឃអគ្រ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៣ ហើយខ្លួនក៏បានពិនិត្យឃើញភាគីទាំងពីរ បានព្រមព្រៀងផ្ទេរសិទ្ធិកាន់កាប់ដីខាងលើពីឈ្មោះ [redacted] ញ៉ូន ឲ្យទៅឈ្មោះ [redacted] វណ្ណៈ ប្រាកដមែន ។

-សាក្សីឈ្មោះ [redacted] សាម៉ៀ ជាអាជ្ញាធរឃុំអូរគ្រៀងបានអះអាងថា ៖ សព្វថ្ងៃនេះខ្លួនជាក្រុមប្រឹក្សាឃុំអូរគ្រៀង ប៉ុន្តែកាលពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០១២ ខ្លួនមានតំណែងជាមេឃុំអូរគ្រៀង ហើយខ្លួនសូមបញ្ជាក់ថាៈ ខ្លួនពិតជាបានចុះហត្ថលេខាបញ្ជាក់លើលិខិតកាន់កាប់ដីធ្លីលេខៈ ៣៨/០៣ ឃអគ្រ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៣ ឲ្យទៅឈ្មោះ [redacted] ញ៉ូន ដោយមានហត្ថលេខារបស់លោកមេភូមិ បញ្ជាក់លើលិខិតកាន់កាប់ដីរបស់ឈ្មោះ [redacted] ញ៉ូន ប្រាកដមែន។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៣ ខ្លួនបានចុះហត្ថលេខាផ្ទេរសិទ្ធិកាន់កាប់ដីពីឈ្មោះ [redacted] ញ៉ូន ឲ្យទៅឈ្មោះ [redacted] វណ្ណៈ ដោយមានភ្ជាប់លិខិតបញ្ជាក់លេខៈ ៣៨/០៣ ឃអគ្រ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៣ និងបានចេញលិខិតចុះលេខៈ ៥៨/០៣ ឃអគ្រ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៣ ហើយឈ្មោះ [redacted] ញ៉ូន ពិតជាបានព្រមព្រៀងផ្ទេរសិទ្ធិកាន់កាប់ដីខាងលើឲ្យទៅឈ្មោះ [redacted] វណ្ណៈ ពិតប្រាកដមែន។

-តាមការអះអាងរបស់ឈ្មោះ [redacted] វណ្ណៈ ជាម្ចាស់ដីបានអះអាងថា ៖ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៣ ខ្លួនបានទិញដីពីឈ្មោះ [redacted] ញ៉ូន ដោយមានលិខិតកាន់កាប់ដីលេខៈ៣៨/០៣ ឃអគ្រ ចុះថ្ងៃទី០១ កុម្ភៈ ឆ្នាំ២០០៣ ឈ្មោះ [redacted] ញ៉ូន បានយល់ព្រមធ្វើលិខិតផ្ទេរសិទ្ធកាន់កាប់ដីមកឲ្យខ្លួនដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខៈ ៥៨/០៣ ឃអគ្រ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៣ ។

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានព្រមព្រៀងលក់ដីនេះឲ្យទៅឈ្មោះ [redacted] ម៉ុងហេង តាមកិច្ច

សន្យាលក់ដី និងប្រាក់កក់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ហើយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ខ្លួនបាន ធ្វើលិខិតផ្ទេរសិទ្ធិឲ្យទៅឈ្មោះ [redacted] ម៉ុងហេង ដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខាការបំពេញបែបបទ និងការទំនាក់ទំនង ជាមួយអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ក្នុងការដោះស្រាយលើបញ្ហាដីធ្លីដូចខាងលើដែលខ្លួនបានលក់ដីនេះទៅឲ្យឈ្មោះ [redacted] ម៉ុងហេង កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ រួចហើយ។

## សំអាងហេតុ

-ពាក្យបណ្ដឹងទាស់ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់សហចុងចម្លើយធ្វើឡើងត្រឹមត្រូវតាមច្បាប់ តែទាស់និងគតិច្បាប់។

-យល់ឃើញថា ពាក្យបណ្ដឹងដិតចិត្តរបស់សហចុងចម្លើយឈ្មោះ [redacted] សេងថៃ និងអ្នកស្រី [redacted] ចំណាន ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ សុំប្ដឹងដិតចិត្តពីចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តក្រចេះ នោះតុលាការមិនអាចលើកយកមកពិនិត្យ និងពិចារណាសម្រេចតាមច្បាប់បានឡើយ ដោយយោងទៅតាមបញ្ញត្តិមាត្រា ២៨ ចំណុច ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

-ការសុំពន្យាពេលជាច្រើនលើក ច្រើនសារ របស់សហចុងចម្លើយធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមចោទ ជាម្ចាស់ក្រុមហ៊ុនជាខ្លាំង តុលាការពុំអាចសម្រេច និងពន្យាពេលតាមការស្នើសុំបានឡើយ។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## សេចក្ដីសម្រេចបញ្ចប់

១/ទទួលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់សហចុងចម្លើយឈ្មោះ [redacted] ចំណាន និង [redacted] សេងថៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែទាស់និងគតិច្បាប់។

២/តំកល់សាលក្រមរដ្ឋវេណីលេខៈ ៣១ (ក) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ទុកជាបានការពេញលេញទាំងមូល ។

៣/សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

៤/ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

ថ្ងៃពុធ ០២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ក្រចេះ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

ចៅក្រម

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

ចៅក្រម

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ០២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ក្រចេះ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]